ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

CAMBODIA

ក្រសួងទេសចរណ៍
អគ្គនាយកដ្ឋានទេសចរណ៍

៤x៦

# ពាក្យសុំអាជ្ញាបណ្ណទេសចរណ៍

ខ្ញុំបាទ/ នាងខ្ញុំឈ្មោះ (ជាអក្សរខ្មែរ និងអក្សរឡាតាំង)..........................................................................
ភេទ............. អាយុ ................ សញ្ជាតិ ......................... ថ្ងៃ ខែ ឆ្នាំ កំណើត ..........................................
អាស័យដ្ឋានបច្ចុប្បន្ន ........................................................................................................................

**សូមគោរពជូន**

**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងទេសចរណ៍**

**កម្មវត្ថុ** ៖សំណើសុំអាជ្ញាបណ្ណទេសចរណ៍សម្រាប់ ការីទេសចរណ៍ នាំភ្ញៀវទៅកម្សាន្តនៅក្រៅប្រទេស (Outbound Tour Operators) ( បដ្ដ )។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុខាងលើ សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាពិនិត្យ និងអនុញ្ញាតផ្ដល់អាជ្ញាបណ្ណទេសចរណ៍ដល់រូបខ្ញុំបាទ/ នាងខ្ញុំជាការីទេសចរណ៍នាំភ្ញៀវទេសចរទៅកម្សាន្តក្រៅព្រះរាជាណាចក្រកម្ពុជាឈ្មោះ (ជាអក្សរខ្មែរ និងអក្សរឡាតាំង) ៖...........................................................................................
...................................................................................................................................
អាស័យដ្ឋាន ...............................................................................................................
ទូរស័ព្ទ ....................................... ទូរសារ....................................... ទូរស័ព្ទដៃ..........................................

សេចក្ដីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាពិនិត្យ និងអនុញ្ញាតដោយសេចក្ដីអនុគ្រោះ។

**សូមគោរពជូនភ្ជាប់មកជាមួយ ៖**

១- លិខិតតម្កល់ប្រាក់ធានាអាជីវកម្មបន្តពីធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា (FTB)( *ច្បាប់ដើម* ).០១ច្បាប់
២- អាជ្ញាបណ្ណទេសចរណ៍ ( *ច្បាប់ដើម* )..........................................................................០១ច្បាប់
៣- របាយការណ៍អំពីសកម្មភាពអាជីវកម្មឆ្នាំមុន..................................................................០១ច្បាប់
៤- កិច្ចសន្យាគោរពច្បាប់រដ្ឋ និងបង្កាន់ដៃបង់ប្រាក់កម្រៃអាជ្ញាបណ្ណទេសចរណ៍ ................................០១ច្បាប់
៥- រូបថតម្ចាស់អាជ្ញាបណ្ណ ( ៤x៦) ................................................................................០៣សន្លឹក

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវសេចក្ដីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ-នាងខ្ញុំ។

ធ្វើនៅ............................ថ្ងៃទី ខែ ឆ្នាំ ២០...

**ស្នាមមេដៃ និងឈ្មោះ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

CAMBODIA
Kingdom of Wonder
feel the warmth

# កិច្ចសន្យារបស់ប្រតិបត្តិករទេសចរណ៍

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ (ជាអក្សរខ្មែរ និងឡាតាំង) ..................................................................................
.................................................... ភេទ ............................ សញ្ជាតិ ............................................
ថ្ងៃ ខែ ឆ្នាំ កំណើត ..............................................................................................................
អាស័យដ្ឋានបច្ចុប្បន្ន ............................................................................................................
ទូរស័ព្ទដៃ ........................................អ៊ីម៉ែល (E-mail) :...................................................................
គេហទំព័រ (Website) :.............................................................................................................

## សូមសន្យា

១- ការបន្តអាជ្ញាបណ្ណទេសចរណ៍ ខ្ញុំបាទ/នាងខ្ញុំ ត្រូវដាក់ពាក្យស្នើសុំមកក្រសួងឱ្យបាន ៣០ (សាមសិប)ថ្ងៃ យ៉ាងតិចមុនថ្ងៃផុតកំណត់សុពលភាពអាជ្ញាបណ្ណ ដោយភ្ជាប់មកជាមួយនូវប្រាក់កម្រៃអាជ្ញាបណ្ណទេសចរណ៍ព្រមទាំងឯកសារ និងព័ត៌មានផ្សេងៗ។

២- ត្រូវដាក់តាំងអាជ្ញាបណ្ណទេសចរណ៍នៅទីកន្លែងដែលងាយមើលឃើញច្បាស់ក្នុងទីបរិវេណធ្វើអាជីវកម្ម។

៣- មុន និងចាប់ផ្តើមប្រកប ឬបិទអាជីវកម្ម ក្នុងករណីមានការផ្ទេរ លក់អាជ្ញាបណ្ណទេសចរណ៍ ប្តូរអ្នកគ្រប់គ្រង ប្តូរនាមករណ៍ ឬប្តូរទីស្នាក់ការ ខ្ញុំបាទ/នាងខ្ញុំត្រូវជូនដំណឹងមកក្រសួងទេសចរណ៍ឱ្យបានមុន៣០(សាមសិប)ថ្ងៃ។

៤- ត្រូវធានាមិនប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈ បរិស្ថាន សុវត្ថិភាព សុខមាលភាពសង្គម និងចូលរួមការពារ និងអភិរក្សមរតកវប្បធម៌ សិល្បៈ ប្រពៃណី ទំនៀមទំលាប់របស់ប្រជាពលរដ្ឋខ្មែរក្នុងរាល់សកម្មភាពអាជីវកម្មរបស់ខ្លួន។

៥- ក្នុងដំណើរការអាជីវកម្មការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍នេះ ខ្ញុំបាទ/នាងខ្ញុំ សន្យាគោរព និងអនុវត្តន៍ឱ្យបានល្អប្រសើរតាមច្បាប់ស្តីពីទេសចរណ៍ និងលិខិតបទដ្ឋានផ្សេងៗរបស់ក្រសួងទេសចរណ៍។

៦- ក្នុងដំណើរការអាជីវកម្ម ខ្ញុំបាទ/នាងខ្ញុំសន្យានឹងមិនជួល ឬចុះកិច្ចសន្យាជាមួយមគ្គុទ្ទេសក៍ទេសចរណ៍ និងអាជីវកម្មសេវាកម្មទេសចរណ៍ដែលគ្មានអាជ្ញាបណ្ណទេសចរណ៍ត្រឹមត្រូវ។

៧- ផ្តល់ដល់ទេសចរនូវព័ត៌មានពិតច្បាស់លាស់ និងទទួលខុសត្រូវផ្តល់សេវាកម្មដូចដែលបានសន្យា ព្រមទាំងមានវិធានការសមស្របដើម្បីថែទាំទ្រព្យសម្បត្តិ ការពារសន្តិសុខ និងសុវត្ថិភាពដល់ទេសចរ និងរាល់ការខូចខាតប៉ះពាល់សម្ភារៈ ឬរូបកាយទេសចរដែលកើតមានឡើងជាយថាហេតុក្នុងពេលធ្វើដំណើរកម្សាន្ត នាងខ្ញុំ/ខ្ញុំបាទនឹងទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។

៨- ខ្ញុំបាទ/នាងខ្ញុំនឹងផ្តល់ជូនក្រសួងទេសចរណ៍ ឬមន្ទីរទេសចរណ៍រាជធានី-ខេត្តឱ្យបានទាន់ពេលវេលានូវស្ថិតិ និងធ្វើរបាយការណ៍ស្តីពីហេតុការណ៍ផ្សេងៗ ដែលទាក់ទងនឹងអាជីវកម្មទេសចរណ៍តាមការស្នើសុំ និងការតម្រូវដោយក្រសួងទេសចរណ៍ ឬមន្ទីរទេសចរណ៍រាជធានី-ខេត្ត។

៩- ត្រូវផ្តល់របាយការណ៍អំពីសកម្មភាពអាជីវកម្មរបស់ខ្លួន និងស្ថិតិភ្ញៀវជូនក្រសួងទេសចរណ៍នៅពេលស្នើសុំបន្តអាជ្ញាបណ្ណទេសចរណ៍។

១០- ត្រូវមានផែនការ និងមានសកម្មភាពបណ្តុះបណ្តាល និងហ្វឹកហ្វឺនដល់បុគ្គលិកបម្រើការងារអំពីជំនាញបដិសណ្ឋារកិច្ច ឬគ្រប់គ្រងទេសចរណ៍ស្របតាមការណែនាំរបស់ក្រសួងទេសចរណ៍។

១១- ម្ចាស់ ឬអ្នកគ្រប់គ្រងត្រូវមានសញ្ញាបត្រកំរិតឧត្តមសិក្សាបញ្ជាក់ការសិក្សាមុខជំនាញបដិសណ្ឋារកិច្ច ឬគ្រប់គ្រងទេសចរណ៍ ឬសញ្ញាបត្រសមមូល (ឬខ្ពស់ជាងនេះ)។

១២- បុគ្គលិកបំរើការត្រូវមានវិញ្ញាបនបត្របញ្ជាក់ការសិក្សាអំពីមុខជំនាញបដិសណ្ឋារកិច្ច ឬគ្រប់គ្រងទេសចរណ៍ដែលទទួលស្គាល់ដោយក្រសួងទេសចរណ៍ (យ៉ាងតិច៣០%នៃចំនួនបុគ្គលិកសរុប)។

១៣- ខ្ញុំបាទ/នាងខ្ញុំសន្យានឹងអនុវត្តតាមប្រភេទអាជ្ញាបណ្ណទេសចរណ៍ និងវិសាលភាពអាជីវកម្មដែលខ្លួនបានស្នើសុំ។

១៤- ត្រូវមានបំពាក់បំពង់ពន្លត់អគ្គីភ័យក្នុងទីស្នាក់ការ និងត្រូវមានច្រកចេញនៅពេលមានអាសន្ន។

១៥- ខ្ញុំបាទ/នាងខ្ញុំនឹងចូលរួមក្នុងយុទ្ធនាការទេសចរម្នាក់ដើមឈើមួយដើម ដើម្បីគាំទ្រ និងចូលរួមចំណែកកាត់បន្ថយផលប៉ះពាល់នៃការកើនឡើងកំដៅផែនដី ។

១៦- ខ្ញុំបាទ/នាងខ្ញុំសន្យាគោរព និងអនុវត្តឱ្យបានម៉ឺងម៉ាត់តាមច្បាប់ស្តីពីទេសចរណ៍ដូចមានចែងក្នុងមាត្រា ៤៤ និងមាត្រា ៤៨។

១៧- ខ្ញុំបាទ-នាងខ្ញុំសន្យាគោរពតាមសេចក្តីណែនាំរបស់ក្រសួងទេសចរណ៍ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីបរិស្ថានគ្មានផ្សែងបារីដល់អ្នកគ្រប់គ្រង ឬម្ចាស់អាជីវកម្មសេវាកម្មទេសចរណ៍ទូទាំងព្រះរាជាណាចក្រកម្ពុជា។

១៨- ខ្ញុំបាទ/នាងខ្ញុំសន្យាគោរព និងអនុវត្តតាមក្រមប្រតិបត្តិវិជ្ជាជីវៈ និងក្រមសីលធម៌វិជ្ជាជីវៈទេសចរណ៍ឱ្យបានល្អ។

១៩- ខ្ញុំបាទ/នាងខ្ញុំ សូមទទួលខុសត្រូវទាំងស្រុងចំពោះការមិនបានអនុវត្តន៍តាមប្រការណាមួយនៃកិច្ចសន្យានេះ។

ធ្វើនៅ.......................... ថ្ងៃ................ ខែ........... ឆ្នាំ................ព.ស.២៥៦១

ត្រូវនឹងថ្ងៃទី.............. ខែ............... ឆ្នាំ ២០...

**ស្នាមមេដៃ និងឈ្មោះ**